ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ១៦ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

៨–៥–៩៥ –ព្រះរាជក្រមលេខ នស/រកម/០៥៩៥/០២ ៦៣៨

២-ព្រះរាជក្រឹត្យ

៥–៥–៩៥ –ព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៥/៤៥ ៦៣៩

II.ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

៥–៥–១៩៩៥ – អនុក្រឹត្យលេខ ៤០ អនក្រ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល ៦៤០

៥–៥–១៩៩៥ – អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៤៧

៦–៥–១៩៩៥ – អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៤៨

២-សេចក្តីសំរេច

៤–៥–១៩៩៤ – សេចក្តីសំរេចលេខ ៣៩ សសរ ស្តីពីការបិទកន្លែងលេងល្បែងស៊ីសងគ្រប់ប្រភេទ ដែលគ្មានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ៦៤៩

៨–៥–១៩៩៥ – សេចក្តីសំរេចលេខ ៤០ សសរ ស្តីពីការបញ្ចូលក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ៦៥០

III.ការចារបណ្ណាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០៦-៥-១៩៩៥ – ប្រកាសលេខ ៣២៣ ឧក.ប្រក អនុញ្ញាតអោយលោក កែវ ណារ៉ា ជនជាតិខ្មែរបើកដំណើរការផលិតកម្មទឹកកកដើម ៦៥១

០៨-៥-១៩៩៥ – ប្រកាសលេខ ៣២៤ ឧក.ប្រក អនុញ្ញាតអោយលោក នួន វណ្ណា ជន ជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៥១

០៨-៥-១៩៩៥ – ប្រកាសលេខ ៣២៥ ឧក.ប្រក អនុញ្ញាតអោយលោក សេង ចិម ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៥២

០៨-៥-១៩៩៥ – ប្រកាសលេខ ៣២៦ ឧក.ប្រក អនុញ្ញាតអោយលោក ឃិន ខន ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៥២

០៨-៥-១៩៩៥ – ប្រកាសលេខ ៣២៧ ឧក.ប្រក អនុញ្ញាតអោយ លោក យឹម សុភ័ក្រ ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ ៦៥៣

០៨-៥-១៩៩៥ – ប្រកាសលេខ ៣២៨ ឧក.ប្រក អនុញ្ញាតអោយអ្នកស្រី ចាប គី ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ៦៥៣

០៨-៥-១៩៩៥ – ប្រកាសលេខ ៣២៩ ឧក.ប្រក អនុញ្ញាតអោយលោក ម៉ា សារី ជនជាតិ ខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ ៦៥៤

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣០ ផក.ប្រក អនុញ្ញាតអោយលោក ម៉េង ហេង ជនជាតិ ខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ៦៥៤

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ស ចាន់ណា ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ៦៥៥

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣២ ផក.ប្រក អនុញ្ញាតអោយលោក សេង ធូ ជនជាតិ ខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៥៥

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣៣ ផក.ប្រក អនុញ្ញាតអោយលោក យន់ សៀង ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ៦៥៦

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣៤ ផក.ប្រក អនុញ្ញាតអោយ អ្នកស្រី អ៊ី ឆេងលន់ ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ៦៥៦

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣៥ ផក.ប្រក អនុញ្ញាតអោយ លោក ជា ណារី ជនជាតិ ខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៥៧

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣៦ ផក.ប្រក អនុញ្ញាតអោយ លោក ផៃ ប៊ុនវ៉ែង ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ ៦៥៧

០៨-៥-១៩៩៥ – ប្រកាសលេខ ៣៣៧ ផក.ប្រក អនុញ្ញាតអោយ លោក ហេង ហឿន ជន ជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៥៨

២-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

២-៥-១៩៩៥	- ប្រកាសលេខ ០៩៣/៩៥ ពម.ប្រក ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រី រាជការ	៦៥៩
២-៥-១៩៩៥	- ប្រកាសលេខ ០៩៤/៩៥ ពម.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រី រាជការ	៦៦០
២-៥-១៩៩៥	- ប្រកាសលេខ ០៩៥/៩៥ ពម.ប្រក ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រី រាជការ	៦៦១
២-៥-១៩៩៥	- ប្រកាសលេខ ០៩៦/៩៥ ពម.ប្រក ស្ដីពីការយល់ព្រម និង ទទួលស្គាល់តាំង ស៊ប់ក្នុងក្របខ័ណ្ឌ	៦៦២
៥-៥-១៩៩៥	- ប្រកាសលេខ ១០១/៩៥ ពម.ប្រក ស្ដីពីការអនុញ្ញាតអោយសារពត៌មាន (ទីយ៉) TUDO ចេញផ្សាយជាភាសាវៀតណាម	៦៦៣
៦-៥-១៩៩៥	- ប្រកាសលេខ ១០២/៩៥ ពម.ប្រក ស្ដីពីការអនុញ្ញាតអោយសារពត៌មាន ឈ្មោះ «ភ្នំពេញប៉ុស្តិ៍» ចេញផ្សាយជាភាសាអង់គ្លេស	៦៦៤
៦-៥-១៩៩៥	- ប្រកាសលេខ ១០៣/៩៥ ពម.ប្រក ស្ដីពីការអនុញ្ញាតអោយកាសែត (LE MEKONG) ដំណើរការបោះពុម្ពផ្សាយ	៦៦៥

៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្ដីសំរេច

៣-៥-១៩៩៥	- សេចក្ដីសំរេចលេខ ២១៩ សសរ.កសក ស្ដីពីការកាត់បន្ថយថ្លៃឈ្នួលឡូត៍ នេសាទដាយលេខ ៨ ហ៊ៀ និង ៨ ហាស់ ខេត្តកណ្ដាល សំរាប់រដូវ ១៩៩៤-៩៥	៦៦៦

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

៥-៥-១៩៩៥ – ប្រកាសលេខ ១០២ ប្រក.វវស.បុ ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ ៦៦៧

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

៣-៥-១៩៩៥ – ប្រកាសលេខ ៤១៩ អយក.ប្រក ស្តីពីការបង្រួមសាលាមធ្យមសិក្សាបីកន្លែង នៅក្រុងកំពត ខេត្តកំពត ៦៦៨

៦-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

៣-៥-១៩៩៥ – ប្រកាសលេខ ២៦៤ ប្រក.មស.បល ស្តីពីការអនុញ្ញាតអោយផ្អាកការងារដោយគ្មានបៀវត្ស ៦៧០

៥-៥-១៩៩៥ – ប្រកាសលេខ ២៧០ ប្រក.មស.បល ស្តីពីបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ ៦៧១

I .ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

ព្រះរាជក្រមលេខ នស/រកម/០៥៩៥/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីប្រកាសបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀង ឥណទាន ចុះថ្ងៃ ទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្តីពី
ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទាន
ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥
រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី

មាត្រា ១: ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានដែលរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នូវទឹកប្រាក់ចំនួន ១៩.១៩៧.000 SDR (ដប់ប្រាំបួនលានមួយ រយកៅសិបប្រាំពីរពាន់ អេស ឌី អរ) តាមឥណទានលេខ ១៣៤៥ CAM (SF) ដើម្បីបំពេញគំរោងការ ស្តារនិងអភិវឌ្ឍន៍អគ្គិសនី ។

មាត្រា ២: ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

២-ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៥/៤៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

– បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានទ្រង់យល់ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឆា ចឺរ៉ាត់** ជាសមាជិក នៃក្រុមប្រឹក្សាភិបាល នៃមូលនិធិសង្គម ជំនួសឯកឧត្តម **ហេង ឧទ្យប៊ុនឆាត**

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា ។

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

II. ឯកសារគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤០ អនក្រ

ស្តីពីលក្ខន្តិកៈរបស់សាលាគួមិន្តរដ្ឋបាល

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ រវាងរដ្ឋាភិបាលសាធារណរដ្ឋបារាំង និង រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំឡើងវិញនូវសាលាភូមិន្ទរដ្ឋបាលប្រចាំនៅកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា លេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមស្មារតីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : សាលាភូមិន្ទរដ្ឋបាល ជាភាសាបារាំងហៅថា Ecole Royal d'Aministration សរសេរអក្សរកាត់ ERA ត្រូវបានបង្កើតឡើងវិញតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ។ សាលាភូមិន្ទរដ្ឋបាល ជាស្ថាប័នមួយដែលមានបុគ្គលិកលក្ខណៈគតិយុត្តិ ហើយចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ។ សាលាភូមិន្ទរដ្ឋបាល មានថវិកាពិសេសមួយបញ្ចូលក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : ទីស្នាក់ការរបស់សាលាភូមិន្ទរដ្ឋបាល តាំងនៅរាជធានីភ្នំពេញ ផ្លូវ ឧកញ៉ាញឹក ជួរមុង «អតីតលេខ ៤៦៦» ខ័ណ្ឌចំការមន ។

មាត្រា ៣ : សាលាភូមិន្ទរដ្ឋបាលមានបេសកកម្មជ្រើសរើស បណ្តុះបណ្តាល និង វិក្រឹតការមន្ត្រីរាជការ ដែលត្រូវគ្រប់គ្រងការងារក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤ : បញ្ជីនៃអង្គ ដែលសាលាភូមិន្ទរដ្ឋបាលត្រូវរៀបចំជ្រើសរើសបណ្តុះបណ្តាល ត្រូវកំណត់តាមបទបញ្ញត្តិនៃលក្ខន្តិកៈ ដែលគ្រប់គ្រងអង្គនានារបស់មន្ត្រីរាជការក្នុងព្រះរាជាណាចក្រកម្ពុជា ឬបើគ្មាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ១

ការរៀបចំរបស់សាលាភូមិន្ទរដ្ឋបាល

មាត្រា ៥ : សាលាភូមិន្ទរដ្ឋបាល ថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតនៅក្រោមការដឹកនាំរបស់នាយកមួយរូប អមដោយក្រុមប្រឹក្សាភិបាលមួយ និងមានជំនួយពីនាយកសិក្សាមួយរូបទទួលបន្ទុកកិច្ចការគរុកោសល្យ ពីនាយកបច្ចេកទេសមួយរូប ឬច្រើនរូបទទួលបន្ទុកកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និង ការរៀបចំកម្មសិក្សា ។

មាត្រា ៦ : នាយកសាលា

- រ៉ាប់រងលើការប្រព្រឹត្តទៅរបស់សាលា អនុវត្តតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល
- ទទួលមើលការគោរពវិន័យផ្ទៃក្នុងដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង
- រៀបចំថវិកា និង គណនេយ្យរដ្ឋបាល និង ហិរញ្ញវត្ថុរបស់សាលា
- បញ្ជាក្នុងការចំណាយសមស្របទៅតាមគម្រោងថវិកាប្រចាំឆ្នាំ
- ចាត់ចែងការប្រឡងប្រជែង និង ការប្រឡងនានាដោយរក្សាគោលការណ៍អនាមិកភាព និង ការកែដោយគ្រូពីរនាក់ ។
- តែងតាំងគ្រូបង្ហាត់ ក្រោយពីមានការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍ ។
- ចាត់ចែងកម្មសិក្សា
- ជ្រើសរើសបុគ្គលិកបង្ហាត់បង្រៀនសំរាប់មុខវិជ្ជា និង រយៈពេលមានកំណត់ និង ភ្នាក់ងារប្រតិបត្តិ
- រៀបចំអង្គការលេខ រៀបចំការប្រព្រឹត្តទៅ និង ការគ្រប់គ្រងរបស់សាលា
- ដាក់ជូនក្រុមប្រឹក្សាភិបាល នូវរបាយការណ៍ប្រចាំឆ្នាំ ស្ដីពីសភាពការណ៍សតិអារម្មណ៍ និង ហិរញ្ញវត្ថុរបស់សាលា និង គម្រោងអភិវឌ្ឍន៍នានា
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងសាលាជាមួយផ្នែករដ្ឋបាល សហគ្រាស អង្គការវិជ្ជាជីវៈខ្មែរ ឬប្រទេសដទៃ ឬជាមួយអង្គការ និង ស្ថាប័នអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ការអនុញ្ញាតពីនាយករដ្ឋមន្ត្រី ។

មាត្រា ៧ : ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី សហប្រធាន
- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មួយរូប សមាជិក
- តំណាងក្រសួងមហាផ្ទៃ មួយរូប សមាជិក

-តំណាងក្រសួងហិរញ្ញវត្ថុ មួយរូប សមាជិក
-តំណាងក្រសួងយុត្តិធម៌ មួយរូប សមាជិក
-តំណាងក្រសួងអប់រំ យុវជន និងកីឡា មួយរូប សមាជិក
-តំណាងរដ្ឋលេខាធិការដ្ឋានទទួលបន្ទុកមុខងារសាធារណៈ មួយរូប សមាជិក
-ឥស្សរជនពីរូបជ្រើសរើសយោលទៅតាមគុណសម្បត្តិ សមាជិក
-នាយកសាលា សមាជិកពេញសិទ្ធិ
-នាយកការសិក្សា សមាជិកអញ្ជើញចូលរួម

ក្រុមប្រឹក្សាភិបាលជ្រើសរើសលេខាធិការមួយរូប ដែលអាចជ្រើសរើសក្នុងចំណោមបុគ្គលិកសាលា ។

មាត្រា ៨ : ប្រធាន និង សមាជិក នៃក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ៩ : ក្រុមប្រឹក្សាភិបាលជាអ្នក :

-យល់ព្រមលើបទបញ្ជាផ្ទៃក្នុង លើកម្មវិធីសិក្សា លើបែបបទចាត់ចែងការប្រឡង និងការប្រឡងប្រជែង លើសមាសភាពគណៈមេប្រយោគ ។
-យល់ព្រមលើគម្រោងថវិកា ។
-អនុញ្ញាតការបង្កើតមជ្ឈមណ្ឌលឧបសម្ព័ន្ធឯកទេស និង យល់ព្រមនូវគម្រោងនានានៃកិច្ចព្រមព្រៀង ដែលមានទំនាក់ទំនងដល់សាលាភូមិន្ទរដ្ឋបាល ទៅនឹងគ្រឹះស្ថាន ឬ ផ្នែកនានារបស់ជាតិ ឬ បរទេស ។
-ត្រួតពិនិត្យការគ្រប់គ្រងរបស់នាយកសាលា និង យល់ព្រមលើរបាយការណ៍ប្រចាំឆ្នាំរបស់នាយកសាលា ។
-ចាត់តាំងនៅក្នុងក្រុមប្រឹក្សា នូវគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ទទួលបន្ទុកជានារ៉ាប់រងដល់ដំណើរការកិច្ចការទូទៅ ។
-ហើយជាទូទៅ សំរេចលើរាល់បញ្ហាស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលា។

មាត្រា ១០: ក្រុមប្រឹក្សាភិបាលប្រជុំពីរដងក្នុងមួយឆ្នាំ តាមសម័យប្រជុំធម្មតានៅសប្តាហ៍ទីមួយ នាខែ ឧសភា និង ខែ កញ្ញា ។

ក្រុមប្រឹក្សាប្រជុំតាមសម័យប្រជុំវិសាមញ្ញ តាមសំណូមពររបស់ប្រធាន របស់នាយកសាលា ឬ របស់សមាជិកចំនួនពាក់កណ្តាលឡើងទៅ ។

ការកោះប្រជុំរបស់ប្រធាន ត្រូវមានភ្ជាប់របៀបវារៈ ។

មាត្រា ១១: ក្រុមប្រឹក្សាភិបាលអាចនឹងសំរេចធ្វើអ្វីបាន លុះណាតែមានអង្គប្រជុំនៃភាគច្រើនរបស់សមាជិក ។ សេចក្តីសំរេចធ្វើឡើងដោយមតិភាគច្រើននៃសមាជិកដែលមានវត្តមាន។ ក្នុងករណីបែងចែកសម្លេង គឺសម្លេងរបស់ប្រធានដែលមានឧត្តមានុភាព ។

មិនអនុញ្ញាតអោយមានតំណាងសមាជិកក្រុមប្រឹក្សា ។ ក្នុងករណីមានកៅអីទំនេរ ត្រូវតែងតាំងអ្នកជំនួសដែលត្រូវបន្តអាណត្តិរបស់អ្នកមុន ។

មាត្រា ១២: គណៈកម្មាធិការអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាភិបាល ដែលបញ្ជាក់ក្នុងមាត្រាទី ៩ រួមមាន នាយកសាលា និង សមាជិកបួនរូប នៃក្រុមប្រឹក្សាដែលចាត់តាំងឡើងនៅផ្ទៃក្នុងរបស់ខ្លួន នៅសម័យប្រជុំសាមញ្ញនាខែ ឧសភា ។ នាយកសិក្សា ត្រូវបានអញ្ជើញអោយចូលរួមក្នុងពេលប្រជុំ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ប្រជុំនៅសប្តាហ៍ទី ៤ នៃរៀងរាល់ខែ ។

គណៈកម្មាធិការរាយការណ៍ទៅក្រុមប្រឹក្សាភិបាលពីការងាររបស់ខ្លួន ។

ជំពូកទី ២

ការជ្រើសរើសចូលសាលាភូមិន្ទរដ្ឋបាល

មាត្រា ១៣: ការចូលរៀននៅសាលាភូមិន្ទរដ្ឋបាល ប្រព្រឹត្តទៅតាមការប្រឡងប្រជែង សំរាប់ការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ និង មន្ត្រីមធ្យម ។ ការចាត់តាំងអាចធ្វើសំរាប់វគ្គសុក្រឹតការ ។

ផ្នែកទី ១

ការបណ្តុះបណ្តាលបឋម

មាត្រា ១៤: សេចក្តីសំរេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី កំណត់ចំនួនកន្លែងផ្តល់ដល់រាល់ការប្រឡងប្រជែង ព្រមទាំងលក្ខ័ណ្ឌប្រឡង មុខវិញ្ញាសា និងសមាសភាពនៃគណៈមេប្រយោគ។

មាត្រា ១៥: មិនអនុញ្ញាតអោយបង្ហាញខ្លួនលើសពីបីដង ក្នុងការប្រឡងប្រជែងចូលជ្រើសរើសមន្ត្រីជាន់ខ្ពស់ ឬ មន្ត្រីមធ្យម ។

មាត្រា ១៦: សិស្ស មិនមែនជាមន្ត្រីដែលបានប្រឡងជាប់ចូលក្នុងសាលាមានគុណសម្បត្តិជាមន្ត្រីកម្មសិក្សា ។ សិស្សទាំងអស់នៅពេលចូលរៀនក្នុងសាលា ត្រូវចុះហត្ថលេខាថា យល់ព្រមបំរើរដ្ឋក្នុងរយៈពេល ៧ ឆ្នាំយ៉ាងតិចរាប់ពីពេលដែលខ្លួនបានត្រូវតែងតាំងមក។

មាត្រា ១៧: កិច្ចការសិស្សត្រូវមានលក្ខណៈជាអនាមិក ហើយត្រូវកែដោយគ្រូពីរនាក់ ។

មាត្រា ១៨: គណៈមេប្រយោគនៃការប្រឡងប្រជែងនីមួយ ។ អាចវាយតម្លៃដោយអធិបតេយ្យនូវចំនួនបេក្ខជនដែលត្រូវឆ្លងវិញ្ញាសាសួរផ្ទាល់មាត់ មុនពេលលើកអនាមិកភាពនៃកិច្ចការសិស្ស ។ ក្នុងករណីមិនដាច់ស្រេច សម្លេងប្រធានមេប្រយោគមានឧត្តមានុភាព ។

ផ្នែកទី ២

វគ្គ សុក្រឹតការ

មាត្រា ១៩: បញ្ជីនៃកម្មសិក្សាការី ដែលទទួលអោយចូលរៀនវគ្គសុក្រឹតការត្រូវកំណត់ដោយសេចក្ដីសំរេចរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី យោងតាមសំណើរបស់រដ្ឋមន្ត្រីនានា និងផ្នែកដែលពាក់ព័ន្ធ ។

មាត្រា ២០: កម្មសិក្សាការីបានត្រូវដាក់ក្នុងស្ថានភាពផ្ដាច់ចេញពីមុខងាររបស់ខ្លួន ក្នុងរយៈពេលសិក្សាវគ្គសុក្រឹតការ ។

ជំពូកទី ៣

សិក្សាគារិកភាពនៅសាលាភូមិន្ទរដ្ឋបាល

ផ្នែកទី ១

ការបណ្ដុះបណ្ដាលបឋម

មាត្រា ២១: ការសិក្សាមានរយៈពេលពីរឆ្នាំ ។ រយៈពេលសិក្សារួមមានការសិក្សា និង ការធ្វើកម្មសិក្សា ដែលទុកជាវិញ្ញាសាសំរាប់ការចាត់ថ្នាក់ ។

មាត្រា ២២: កម្មវិធីសិក្សា និង កម្មវិធីកម្មសិក្សា ត្រូវរៀបចំឡើងដោយនាយកសាលាតាមការស្នើរបស់នាយកសិក្សា ។ កម្មវិធីនោះត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។

មាត្រា ២៣: ការសិក្សាអាចបំពេញបន្ថែមនៅពេលចេញពីសាលា ដោយការបណ្ដុះបណ្ដាលឯកទេស ដើម្បីសំរេចអោយបានសមស្របទៅនឹងមុខងារ ។ ដូច្នេះត្រូវមានកិច្ចព្រមព្រៀងរវាងសាលាភូមិន្ទរដ្ឋបាល និងរដ្ឋបាលសាមី ដើម្បីធ្វើបែបបទបណ្ដុះបណ្ដាល។

ផ្នែកទី ២

វគ្គសុក្រឹតការ

មាត្រា ២៤: វគ្គសុក្រឹតការមានរយៈពេល ៩ ខែ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើកម្មសិក្សាភាសាជាមុន ។ វគ្គសុក្រឹតការ មិនមានការចាត់ថ្នាក់នៅពេលចេញទេ ។

មាត្រា ២៥: កម្មសិក្សាការីដែលទទួលបានពិន្ទុលើសពីមធ្យមក្នុងពេលសិក្សា ត្រូវទទួលនូវវិញ្ញាបនបត្រសិក្សាមួយហើយអាចទទួលបាននូវការឡើងឋានន្តរសក្តិ ។

ជំពូកទី ៤

ការចាត់ថ្នាក់ពេលចេញពីសាលា

មាត្រា ២៦: សេចក្ដីសំរេចរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី បញ្ជាក់ពីអាជីពដែលបើកអោយមានដល់សិស្សមន្ត្រីជាន់ខ្ពស់ និង មន្ត្រីមធ្យម ពីការតែងតាំងគណៈមេប្រយោគ ទទួលបន្ទុករៀបចំការចាត់ថ្នាក់របស់សិស្សទាំងនោះ និង បញ្ជាក់ពីមុខ និង ចំនួនវិញ្ញាសា ។

ការចាត់ថ្នាក់ត្រូវរៀបចំទៅតាមពិន្ទុសរុប ទទួលបានដោយសិស្សម្នាក់ ៗ ដោយបូកបញ្ចូល គិតដល់មេគុណទៀតផង នូវពិន្ទុកម្មសិក្សា ពិន្ទុត្រួតពិនិត្យប្រចាំ និង ពិន្ទុប្រឡង ។

មាត្រា ២៧: សិស្សទាំងឡាយដែលបានមានឈ្មោះក្នុងបញ្ជីប្រឡងជាប់ជ្រើសរើសអង្គ រដ្ឋបាលរបស់ខ្លួនដែលគេនឹងត្រូវបំពេញការងារយោលទៅតាមលេខចាត់ថ្នាក់ ។

ពួកគេនឹងទទួលបានការតាំងស៊ុបក្នុងក្របខ័ណ្ឌ ក្រោយពីធ្វើកម្មសិក្សាសាកល្បងរួចមក ។

មាត្រា ២៨: មេប្រយោគមិនចុះឈ្មោះសិស្សដែលបានពិន្ទុក្រោមមធ្យម លើបញ្ជីចាត់ថ្នាក់ទេ ។

មាត្រា ២៩: សិស្សដែលមិនបានបញ្ចប់រយៈពេលសិក្សាដោយជោគជ័យ ដោយមានមូលហេតុអ្វីក៏ដោយមិនអាចទុកខ្លួនថា មានគុណសម្បត្តិជាអតីតសិស្សសាលាភូមិន្ទរដ្ឋបាលឡើយ។

បទបញ្ញត្តិផ្សេង ៗ

មាត្រា ៣០: បទបញ្ជាផ្ទៃក្នុងដែលរៀបចំដោយនាយកសាលា ក្រោយពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល បញ្ជាក់នូវសិទ្ធិ និង កាតព្វកិច្ចនៃសិស្ស និង កម្មសិក្សាការី នូវលក្ខ័ណ្ឌនៃសិក្ខាគារិកភាព និង របបវិន័យ ។

មាត្រា ៣១: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣២: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្ដាក្រសួងពាក់ព័ន្ធ នាយកសាលាភូមិន្ទរដ្ឋបាល និង ក្រុមប្រឹក្សាភិបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥១ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសេចក្តីសុំលាលែងរបស់ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស**
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **អ៊ុត ទិជិត** ជាប្រធានក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ជំនួសព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីជនដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់មន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំងលោក **អ៊ុច ស៊ីសាចដា** ជាទីប្រឹក្សាអមស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង លោក **អ៊ុច ស៊ីសាចដា** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ: ៣៩ សសរ

ស្តីពីការបិទកន្លែងលេងល្បែងស៊ីសងគ្រប់ប្រភេទ
ដែលគ្មានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១: ហាមមិនអោយមានកន្លែងលេងល្បែងស៊ីសងគ្រប់ប្រភេទ ដែលគ្មានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា និងបិទជាស្ថាពរនូវកន្លែងលេងល្បែងស៊ីសងគ្រប់ប្រភេទដែលគ្មានគោលការណ៍ អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ២: ប្រគល់ភារកិច្ចជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់ផ្នែកដែលមានការពាក់ព័ន្ធ ដើម្បីសហការអនុវត្តបិទកន្លែងលេងល្បែង ដូចបានកំណត់ក្នុងប្រការ ១ អោយទទួលបានប្រសិទ្ធភាព ខ្ពស់ក្នុងរយៈពេល ០៧ ថ្ងៃ ចាប់តាំងពីសេចក្តីសំរេចនេះ ត្រូវបានប្រមុខនៃរាជរដ្ឋាភិបាលឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខា ។

ប្រការ ៣ : រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ នាយអគ្គសេនាការកងយោធពល ខេមរភូមិន្ទ បញ្ជាការកងរាជអាវុធហត្ថ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ

នៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ: ៤០ សសរ

ស្តីពីការបញ្ចូលក្របខ័ណ្ឌរដ្ឋបាលស៊ីវិល

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់គណៈបក្ស ហ៊្វុនស៊ិនប៉ិច
- បានឃើញចំណារយល់ព្រមរបស់សម្តេចនាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានបញ្ចូលមន្ត្រី បុគ្គលិករដ្ឋបាលស៊ីវិល អតីតរចនាសម្ព័ន្ធរដ្ឋបាល របស់គណៈបក្សហ៊្វុនស៊ិនប៉ិច ចំនួន ៤១៨៣ នាក់ «បួនពាន់មួយរយប៉ែតសិបបីនាក់» ទៅក្នុងក្របខ័ណ្ឌ រដ្ឋបាលស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ស្រុក ខេត្ត និង ក្រុង ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ឯកឧត្តម អភិបាលខេត្ត-ក្រុង មានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១

ព្រះហស្តលេខា និង ត្រា

នរោត្តម រណឫទ្ធិ

III. ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៣២៣ ឧក.ប្រក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **កែវ ណារ៉ា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ០២១១១៧ កក.៤ ចុះថ្ងៃទី ១៨-១២-៩០ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ១៨ ភូមិថ្មស ឃុំថ្មស ស្រុក បូទុមសាគរ ខេត្តកោះកុង បើកដំណើរការផលិតកម្មទឹកកកដើមនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលមានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣២៤ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ខួន ចន្ថា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ៣៩៧៩០៩ ក.ណ ចុះថ្ងៃទី ២៨-០១-៩៤ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរអណ្តូង ឃុំចាត្វរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២: លោក **ខួន ចន្ថា** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣២៥ ផក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **សេខ ចិម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ២២៥៣៩៧ ក.ណ ចុះថ្ងៃទី ១០-១២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២ ភូមិអញ្ចាញ ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បើកដំណើការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **សេខ ចិម** ត្រូវចាប់ផ្តើមការដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * *

ប្រកាសលេខ ៣២៦ ផក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឃិន ខន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ២២៥៦៨៥ ក.ណ ចុះថ្ងៃទី ១១-១២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ១ ភូមិដូង ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បើកដំណើការ រោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឃិន ខន** ត្រូវចាប់ផ្តើមការដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣២៧ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **យឹម សុគន្ធា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណ លេខ ១៣៧៧១៦ ក.ឆ ចុះថ្ងៃទី ០៦–៦–៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិជ្រៃលាស់ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល បើកដំណើការ រោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **យឹម សុគន្ធា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * *

ប្រកាសលេខ ៣២៨ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ខាម គី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណ លេខ ១២៥៧៥៨ ក.ណ ចុះថ្ងៃទី ១៧–១០–៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិពុកឫស្សីលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បើកដំណើការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ខាម គី** ត្រូវចាប់ផ្តើមការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣២៩ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ា សាទី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ០៤៥៨១១ សរ. ចុះថ្ងៃទី ១២-៨-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៤ ភូមិអន្លង់ត្នោត ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប បើកដំណើការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ម៉ា សាទី** ត្រូវចាប់ផ្តើមការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * * *

ប្រកាសលេខ ៣៣០ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង ម៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ៣៥២៨៤៧ ភ.ព ចុះថ្ងៃទី ០២-៥-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិចំការនិគ្រោធ សង្កាត់កាកាប ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ បើកដំណើការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ហេង ម៉េង** ត្រូវចាប់ផ្តើមការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * *

ប្រកាសលេខ ៣៣១ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស ចាន់ណា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ១១៨៥៤៥ ភ.ព ចុះថ្ងៃទី ០២-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០ ផ្លូវលេខ ២ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ បើកដំណើការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំងភូមិទី ២៤ សង្កាត់ព្រៃស ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : អ្នកស្រី **ស ចាន់ណា** ត្រូវចាប់ផ្តើមការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * *

ប្រកាសលេខ ៣៣២ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **សេខ ឆ្នូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ០៣៩៤៧៦ ក.ស្ព ចុះថ្ងៃទី ០៨-១១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំណាប់ ឃុំលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បន្តដំណើការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំងភូមិស្ទឹង ឃុំលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រការ ២ : លោក **សេខ ឆ្នូ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * *

ប្រកាស លេខ ៣៣៣ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **យន់ សៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៩០៨៦៥ ប.ប ចុះថ្ងៃទី ១៦-៧-៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ គារ ២ ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីន កិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិ ព្រៃកអាំ ឃុំ របស់មង្គល ស្រុក មោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **យន់ សៀង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣៣៤ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អ៊ូ សេងលន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨២១០១ ភ.ព ចុះថ្ងៃទី ១៥-៨-៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥ សេអឺ០ ផ្លូវ លេខ ១៩០ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំង ក្រុមទី ៤ ភូមិ ពោធិវិទ្ធិគ្រៃ ឃុំស្វាយ ស្រុក សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : អ្នកស្រី **អ៊ូ ឆេងលន់** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣៣៥ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ រោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ខា ណារី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨៣៨៦៤ ប.ប ចុះថ្ងៃទី ២៣–២–៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២ ភូមិ តាគុត ២ ឃុំមោង ស្រុកមោងឫស្សី ខេត្ត បាត់ដំបង បើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ២៤ សេះ នៅក្នុងទីតាំង ដូច អាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ខា ណារី** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣៣៦ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក **ង៉ែ ម៉ិនទ័រ** សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤០៩៦៦ ក.ណ ចុះថ្ងៃទី ១៨–១០–៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកដូនហែម ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣០ សេះ នៅក្នុង ទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ឆែ ម៉ុងឆេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣៣៧ ឧក.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង ហ៊ឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៩៧៦៧ ក.ណ ចុះថ្ងៃទី ១៨–១០–៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកលោក ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ភូមិ លេខ ៤ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ។

ប្រការ ២ : លោក **ហេង ហ៊ឿន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

* * *

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ០៩៣/៩៥ ព.ម.ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រី រាជការ

* * *

- បានឃើញ ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យលើមតិយល់ព្រមបញ្ជូនលេខ ០៩១ រ.ប.៩៥ ចុះថ្ងៃទី ០៥-៤-១៩៩៥ របស់ អគ្គនាយក ដ្ឋាន វិទ្យុជាតិកម្ពុជា
- ពិនិត្យលើសំណើសុំផ្លាស់ប្តូរកន្លែងធ្វើការរបស់សាមីខ្លួន

សំរេច

ប្រការ ១ : យល់ព្រមជូនអ្នកស្រី **ខុំ សាមីន** អនុប្រធានការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន វិទ្យុជាតិ ផ្លាស់អោយទៅធ្វើការនៅ មន្ទីរពតិមានខេត្ត រតនគីរី ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន អគ្គនាយកដ្ឋានវិទ្យុជាតិ ត្រូវផ្ទេរផ្តាច់ទៅ មន្ទីរពតិមានខេត្ត ចាប់ពីថ្ងៃទី ០១ ខែ ០៦ ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញវត្ថុ នាយកដ្ឋាន បុគ្គលិក រដ្ឋបាល និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ថ្ងៃចុះ ហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង-មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ០៩៤/៣.ម.ប្រក

ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ

* * *

- បានឃើញ ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសំណើលេខ ០៩៦-៩៥ សពខ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ «អា.កា.ប៉េ»
- ពិនិត្យលើពាក្យសុំឈប់របស់សាមីខ្លួន

សំរេច

ប្រការ ១ : លុបឈ្មោះ លោក **ឌឹត ចាន់សឿន** បុគ្គលិកបច្ចេកទេស នៃ អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ ចេញពីបញ្ជីក្របខ័ណ្ឌក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៥ នេះទៅ ដោយសាមីខ្លួនដាក់ពាក្យសុំឈប់ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ។ របស់សាមីខ្លួន ត្រូវបានឧបត្ថម្ភម្ដងគត់ ដោយស្មើនឹងប្រាក់បៀវត្សដូចខាងក្រោម :

៤១.៤៩០រ00 គុណ ៥ : ២០៧.៤៥០រ00

ប្រការ ៣ : អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក រដ្ឋបាល និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាស ចាប់ថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង–មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ០៩៥/ព.ម.ប្រក

ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

* * *

– បានឃើញ ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– យោងការយល់ព្រមរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុវនិតិសម្បទា ចុះថ្ងៃទី ០៤-៤-១៩៩៥

– ពិនិត្យលើសំណើសុំផ្លាស់ប្ដូរកន្លែងធ្វើការរបស់សាមីខ្លួន

សំរេច

ប្រការ ១ : យល់ព្រមផ្លាស់កន្លែងធ្វើការជូនលោក **ឈុំ ផា** បុគ្គលិក អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា ផ្លាស់ទៅបំរើការងារនៅក្រសួង យុវនិតិសម្បទាវិញ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ត្រូវផ្ទេរផ្ដាច់ទៅអោយអង្គភាពថ្មី ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា នាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងសាមីខ្លួន មានភារៈអនុវត្តតាមប្រកាសចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង-មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ០៩៦/៩៥ ព.ម.ប្រក

ស្តីពីការយល់ព្រម និង ទទួលស្គាល់តាំងស៊ប់ក្នុងក្របខ័ណ្ឌ

* * *

–បានឃើញ ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–យោងសំណើសេចក្តីសំរេច លេខ ០៦១–៩៤ ព.ម ស.រ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៤ របស់ក្រសួងពត៌មាន

–ពិនិត្យសំណើលេខ ០៣–៩៥ ទទក ចុះថ្ងៃទី ១០ ខែ ៤ ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋានទូរទស្សន៍កម្ពុជា

សំរេច

ប្រការ ១ : យល់ព្រម និង ទទួលស្គាល់ លោក **លុយ សំអាត** កម្មករជំនាញបច្ចេកទេសវិទ្យុនិងទូរទស្សន៍ អោយតាំងស៊ប់ ក្នុងក្របខ័ណ្ឌអគ្គនាយកដ្ឋាន ទូរទស្សន៍ នៃក្រសួងពត៌មាន ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន ត្រូវបានទទួល ១០០ ភាគរយ ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៥ នេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ទូរទស្សន៍ នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងសាមីខ្លួន មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង–មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ១០១/៩៥ ព.ម.ប្រក

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃ រដ្ឋកម្ពុជា អនុម័ត នាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំអនុញ្ញាតបោះពុម្ពផ្សាយ សារពត៌មាន ឈ្មោះ «ទឺយ៉» (TU DO) ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៥ .

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ (ទឺយ៉) TỤ DO ចេញផ្សាយជាភាសាវៀតណាម ដោយមានលោក **លី ចាន់តារា** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ។

ប្រការ ៤ : លោក **លី ចាន់តារា** ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ១០២/៩៥ ព.ម.ប្រក

* * *

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី១៣៩

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃ រដ្ឋកម្ពុជា អនុម័ត នាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១

– បានឃើញលិខិតស្នើសុំអនុញ្ញាតបោះពុម្ពផ្សាយកាសែត «ភ្នំពេញ ប៉ុស្តិ៍ » ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ «ភ្នំពេញ ប៉ុស្តិ៍ » ចេញផ្សាយជាភាសាអង់គ្លេស ដោយមានលោក MICHAEL HAYES ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និង ប្រគល់សារពត៌មាន ចំនួន ១៥ ច្បាប់មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក MICHAEL HAYES ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃ ក្រសួង ពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ១០៣/៩៥ ព.ម.ប្រក

* * *

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានប្បញ្ញត្តិ មាត្រាទី១៣៩

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់សារព័ត៌មាន ត្រូវបានរដ្ឋសភា នៃ រដ្ឋកម្ពុជា អនុម័ត នាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១

– បានឃើញលិខិតស្នើសុំអនុញ្ញាតប្តូរឈ្មោះ និពន្ធនាយកគ្រប់គ្រងកាសែត (LE MEKONG) ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែត (LE MEKONG) ដំណើរការបោះពុម្ពផ្សាយដោយមានលោក MARC VICTOR ជានិពន្ធនាយក និង គ្រប់គ្រងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និង ស្នើយកសារព័ត៌មានចំនួន ១៥ ច្បាប់ មកតំកល់ទុកនៅក្រសួងព័ត៌មាន ។

ប្រការ ៤ : លោក MARC VICTOR និពន្ធនាយក និង នាយកដ្ឋានមណ្ឌលព័ត៌មាន នៃ ក្រសួង ព័ត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៣-ឥស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២១៩ សសរ.កសក

ស្តីពីការកាត់បន្ថយថ្លៃឈ្នួលឡូត៍នេសាទជាយ
លេខ ៨ ហៀ្យ និង ៨ ហាស់ ខេត្តកណ្តាល
សំរាប់រដូវ ១៩៩៤-៩៥

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យ-ច្បាប់ លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៨៩ ស្តីពីការជួលដែននេសាទទឹកសាប និង សមុទ្រ អោយធ្វើអាជីវកម្ម
- បានឃើញសេចក្តីសំរេចលេខ ២៨២ សសរ.កសក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការប្រគល់សិទ្ធិអោយអ្នកដែលដេញថ្លៃឈ្នួលឡូត៍នេសាទបាន និង អ្នកសុំជួលធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទតាមបណ្តាខេត្ត-ក្រុង សំរាប់រដូវនេសាទ ១៩៩៣-៩៤ និង ១៩៩៤-៩៥ ។
- តាមសំណើរបស់នាយកដ្ឋានជលផល លេខ ៣០០ ជផ.អជក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : កាត់បន្ថយថ្លៃឈ្នួលឡូត៍ដាយលេខ ៨ ហៀ្ស និង ៨ ហាស់ ខេត្តកណ្តាលសំរាប់រដូវនេសាទ ១៩៩៤-៩៥ ចំនួន ១៥.០០០.០០០រ០០ ដើម្បីសំរួលក្នុងការខាតបង់ ដែលរងគ្រោះដោយនាវារបស់កងនាវាចរមូលដ្ឋានទន្លេ ប៉ះពារបណ្តាលអោយមានការខូចខាតយ៉ាងធ្ងន់ធ្ងរ ។

ប្រការ ២ : សេចក្តីសំរេចណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្មខេត្តកណ្តាល ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
អនុរដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ម៉ៅ សំអឿន

* * *

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

ប្រកាស លេខ ១០២ ប្រក.វវស.មុ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញលិខិតរបស់អាជ្ញាធរអាកាសចរស៊ីវិល លេខ ១៨៥–៩៥ អ.អសពក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៥ ។

សំរេច

មាត្រា ១ : លោក **ឌី សារឡា** បុគ្គលិកសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅអាជ្ញាធរអាកាសចរស៊ីវិល ។

មាត្រា ២ : ក្រសួងនឹងផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេង ៗ របស់លោក **ឌី សារឡា** ព្រមទាំងក្របខ័ណ្ឌមួយកន្លែងជូនអាជ្ញាធរអាកាសចរស៊ីវិល ។

មាត្រា ៣ : អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង លោក **ឌី សារឡា** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ីសុវត្ថិ ស៊ីវុធ ចាំណារ៉ា

* * *

៥-នីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

ប្រកាស លេខ ៤១៩ អយក.ប្រក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

ស្តីពីការបង្រួមសាលាមធ្យមសិក្សាបឹកន្លែង

នៅក្រុងកំពត–ខេត្តកំពត

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពតលេខ ១៦០ អយកខ.ចទម ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤ ដោយមានការឯកភាព ពីអភិបាលខេត្តកំពត
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយបង្រួមវិទ្យាល័យកំពតក្រុង អនុវិទ្យាល័យកំពតក្រុង និង អនុវិទ្យាល័យទីរួមខេត្ត ជាសាលារៀនតែមួយ ដែលមានឈ្មោះថា «វិទ្យាល័យព្រះរាជសម្ភារ» និងមានទីតាំងនៅមូលដ្ឋានដើម ដូចកាលសម័យ សង្គមរាស្ត្រនិយម នៅក្រុងកំពត ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ១៩៩៤–៩៥ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិក ផ្សេងៗ មួយចំនួនទៀត តាមអង្គការលេខ នៃវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច របស់នាយក នាយករង នៃវិទ្យាល័យ ។

មាត្រា ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានផែនការ–ហិរញ្ញកិច្ច និង ប្រធាននាយកដ្ឋានបាត់តាំង នៃ ក្រសួងអប់រំ យុវជន និង កីឡា មាន ភារកិច្ចរៀង ។ ខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៦-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ២៦៤/៩៥ ប្រក.មស.បល

ស្តីពីការអនុញ្ញាតអោយផ្អាកការងារដោយគ្មានបៀវត្សបន្ត

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៨៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញសារាចរណែនាំលេខ ០៣ សរ. ចុះថ្ងៃទី ០៥-៣-១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការស៊ីវិលផ្អាកការងារមួយរយៈដោយគ្មានបៀវត្ស
- ពិនិត្យពាក្យស្នើសុំរបស់សាមីខ្លួន ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អ៊ុក សំចិត្តណ្ណារី** ផ្អាកការងារដោយគ្មានបៀវត្សរយៈពេលមួយឆ្នាំបន្តទៀត ដោយគិតចាប់ពីថ្ងៃទី ០១-៥-១៩៩៥ ដល់ថ្ងៃទី ៣០-៤-១៩៩៦។

ប្រការ ២ : ក្របខ័ណ្ឌអ្នកស្រី **អ៊ុក សំចិត្តណ្ណារី** ត្រូវរក្សាទុកក្នុងអង្គភាពរបស់ខ្លួនដដែល ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានបៀវត្ស នាយកដ្ឋានក្របខ័ណ្ឌ និង សាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

ប្រកាសលេខ: ២៧០ ប្រក.មស.បល

ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ០៧៥ សសរ.មសក្រខ ចុះថ្ងៃទី ២២-៣-១៩៩៣៥ ស្តីពីការបែងចែកសិស្សនិស្សិត របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

ប្រការ ១ : បញ្ចូលលោក **ឈី ហេង** កើតនៅថ្ងៃទី ៧ ខែ មិនា ឆ្នាំ ១៩៧៤ ក្នុងក្របខ័ណ្ឌបៀវត្ស នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ប្រការ ២ : លោក **ឈី ហេង** ត្រូវធ្វើកម្មសិក្សាចំនួន ១២ ខែ គិតពីថ្ងៃទី ០១-៨-១៩៩៥ ដល់ថ្ងៃទី ០១-៣-១៩៩៦ ដោយទទួលប្រាក់បៀវត្ស ៩០ ភាគរយ នៃកាំប្រាក់ ឱ.១ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានបៀវត្ស នាយកដ្ឋានក្របខ័ណ្ឌ និង សាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់